# ព្រះរាជក្រម

នស/រកម/០៤២០/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២០២/០០២/២០២០ កបធ.ច ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# ការគ្រប់គ្រងប្រទេសជាតិ
# ស្ថិតក្នុងភាពអាសន្ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះកំណត់អំពីបែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ននៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រមទាំងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ននេះ ក្នុងគោលបំណងដើម្បីការពារសន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិនិងបរិស្ថាន។

**មាត្រា២ .- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តនៅពេលដែលប្រទេសជាតិត្រូវបានដាក់ស្ថិតក្នុងភាពអាសន្ន ស្របតាមមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## បែបបទ នីតិវិធី និងលក្ខខណ្ឌ
## នៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

**មាត្រា៣.- បែបបទនិងនីតិវិធីនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។

ការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចធ្វើឡើងសម្រាប់ថិរវេលាមិនឱ្យលើសពី ៣(បី)ខែ។ ថិរវេលានេះអាចត្រូវប្រកាសបន្តបានក្នុងលក្ខខណ្ឌដូចគ្នា។ កាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចត្រូវបញ្ចប់ទៅវិញដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា កាលបើកាលៈទេសៈពិសេសនេះបានចប់ទៅវិញមុនកាលកំណត់នៃថិរវេលាដែលមានចែងនៅក្នុងព្រះរាជក្រឹត្យទាក់ទងនឹងការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

នៅគ្រប់ករណីទាំងអស់ រដ្ឋសភាឬព្រឹទ្ធសភាមានសិទ្ធិបញ្ចប់កាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន កាលបើសភាពការណ៍អនុញ្ញាត ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីមានការសម្រេចរបស់រដ្ឋសភាឬព្រឹទ្ធសភា ការបញ្ចប់កាលៈទេសៈពិសេសនេះត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។

បើរដ្ឋសភាឬព្រឹទ្ធសភាមិនអាចប្រជុំបានទេដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

## មាត្រា៤ .- លក្ខខណ្ឌនៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចធ្វើឡើងនៅពេលដែលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាមឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលគំរាមកំហែងឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

## ជំពូកទី៣
## ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

## មាត្រា៥ .- វិធានការក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

នៅពេលប្រទេសជាតិត្រូវបានប្រកាសដាក់ស្ថិតនៅក្នុងភាពអាសន្ន រាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញវិធានការដូចខាងក្រោម៖

-ការហាមឃាត់ឬការកម្រិតសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ។

-ការហាមឃាត់ឬការកម្រិតសិទ្ធិសេរីភាពក្នុងការជួបជុំឬការប្រមូលផ្តុំមនុស្ស។

-ការហាមឃាត់ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរ។

-ការហាមឃាត់ឬការកម្រិតមិនឱ្យបុគ្គលចេញពីលំនៅឋានឬទីសំណាក់ណាមួយ។

-ការដាក់ចេញវិធានការចត្តាឡីស័កឬការដាក់ឱ្យនៅដោយឡែកក្នុងករណីគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ។

-ការដាក់ចេញវិធានការទាក់ទងនឹងកំណែននិងជម្លៀសពលរដ្ឋ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

-ការដាក់ចេញវិធានការទាក់ទងនឹងកំណែន ការដកហូត ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិនិងសេវារបស់រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានភាពចាំបាច់ដើម្បីឆ្លើយតប

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ចំពោះភាពអាសន្ន។ នីតិវិធីនៃកំណែន ការដកហូត ការគ្រប់គ្រង ការចាត់ចែង ព្រមទាំងការផ្តល់សំណងត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

-ការដាក់ចេញវិធានការទាក់ទងនឹងការកំណត់ថ្លៃទំនិញនិងសេវា ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

-ការដាក់ចេញវិធានការទាក់ទងនឹងការបិទទីតាំងសាធារណៈឬឯកជនណាមួយ ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

-ការដាក់ចេញនូវវិធានការឃ្លាំមើលនិងតាមដានតាមគ្រប់មធ្យោបាយ ដើម្បីទទួលបានព័ត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍គ្រប់រូបភាព ក្នុងគោលបំណងឆ្លើយតបចំពោះភាពអាសន្ន។

-ការហាមឃាត់ ឬការកម្រិតការចែកចាយឬការផ្សព្វផ្សាយព័ត៌មានដែលអាចបង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ឬចលាចល ឬដែលនាំឱ្យខូចខាតដល់សន្តិសុខជាតិ ឬធ្វើឱ្យមានការភាន់ច្រឡំអំពីស្ថានភាពនៃភាពអាសន្ន។

-ការដាក់ចេញវិធានការដទៃទៀតដែលសមស្របនិងចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

វិធានការអនុវត្តពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចត្រូវបានដាក់ចេញសម្រាប់ទូទាំងប្រទេស ឬដែនដីកំណត់ជាក់លាក់ណាមួយ។

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចបង្កើតយន្តការឬប្រគល់សិទ្ធិអំណាចទៅអាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាដល់ការអនុវត្តវិធានការខាងលើ។

ក្នុងពេលសង្គ្រាមឬក្នុងកាលៈទេសៈដទៃទៀតដែលសន្តិសុខជាតិប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយរាជរដ្ឋាភិបាល អាចធ្វើឡើងតាមរបបអាជ្ញាសឹក។

## មាត្រា៦ .- របាយការណ៍អំពីវិធានការក្នុងភាពអាសន្នជូនរដ្ឋសភានិងព្រឹទ្ធសភា

រាជរដ្ឋាភិបាលត្រូវរាយការណ៍ជាប្រចាំអំពីវិធានការដែលខ្លួនបានដាក់ចេញក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ជូនទៅរដ្ឋសភានិងព្រឹទ្ធសភា។ រដ្ឋសភានិងព្រឹទ្ធសភាអាចស្នើសុំព័ត៌មានចាំបាច់បន្ថែមផ្សេងទៀតពីរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងការវាយតម្លៃអំពីវិធានការដែលបានដាក់ចេញក្នុងពេលដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា៧ .- បទរារាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនារារាំងឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការឆ្លើយតបចំពោះភាពអាសន្ន ឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

អំពើរារាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ កាលបើអំពើនេះនាំឱ្យមានចលាចលជាសាធារណៈឬប៉ះពាល់ដល់សន្តិសុខជាតិ។

**មាត្រា៨ .- បទមិនគោរពវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការដាក់ចេញដោយរាជរដ្ឋាភិបាលក្រោមបញ្ញត្តិនៃមាត្រា៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល។

អំពើមិនគោរពតាមវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើនេះនាំឱ្យមានចលាចលជាសាធារណៈ។

**មាត្រា៩ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៧នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០(មួយរយលាន)រៀល ទៅ ១.០០០.០០០.០០០(មួយប៊ីលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា៨នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០(ហាសិបលាន)រៀល ទៅ ៥០០.០០០.០០០(ប្រាំរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា១០ .- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពាន ខុសពីគោលបំណងនៃច្បាប់នេះ ហើយបង្កការប៉ះពាល់ដល់រូបរាងកាយឬការខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .- ការប្រកាសជាការប្រញាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២០

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពស.២០០៤-៤៩១

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**